ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

# ច្បាប់

# ស្តីពី

# ការបង្ក្រាបអំពើពង្រត់និងលក់ដូរមនុស្ស
# និងអំពើធ្វើអាជីវកម្មលើមនុស្ស

ទទួលលិខិត
ចូល
លេខ...៤៥៥...
ថ្ងៃទី១...៣...៩៦ម៉ោង១១:៣០
បញ្ជូនទៅ...

នស / រកម / ០២៩៦ / ០១

# ព្រះរាជក្រម

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * * * * * * * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស-៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត-១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ១៩៩៤ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត-១០៩៤-៨០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស-រកម-០១៩៦-០៤ ចុះថ្ងៃទី ២៤ខែមករាឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និង របស់ទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់និងលក់ដូរមនុស្ស និង អំពើធ្វើអាជីវកម្មលើមនុស្សដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៩៦ ក្នុងសម័យប្រជុំលើកទី ៤ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ច្បាប់
## ស្ដីពី
## ការបង្ក្រាបអំពើពង្រត់និងលក់ដូរមនុស្ស
## និងអំពើធ្វើអាជីវកម្មលើមនុស្ស

### ជំពូកទី ១
### បទបញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅបង្ក្រាបអំពើពង្រត់មនុស្សយកទៅលក់ដូរ និងអំពើធ្វើអាជីវកម្មលើមនុស្ស ដើម្បីធ្វើនីតិសម្បទានិងលើកកំពស់ការគោរពប្រពៃណីជាតិល្អ ការការពារសេចក្ដីថ្លៃថ្នូររបស់មនុស្សនិងការការពារសុខភាពនិងសុខុមាលភាពរបស់ប្រជាជន ។

**មាត្រា ២.-**

ត្រូវហាមឃាត់ដាច់ខាតអំពើពង្រត់មនុស្សយកទៅលក់ដូរ ឬយកទៅធ្វើពេស្យាចារនិងអំពើធ្វើអាជីវកម្មលើមនុស្សនៅក្នុងឬក្រៅទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ។

### ជំពូកទី ២
### អំពីអំពើពង្រត់មនុស្សយកទៅលក់
### ឬយកទៅធ្វើពេស្យាចារ

**មាត្រា ៣.-**

ជនណាអូសទាញមនុស្ស ទោះបីស្រីឬប្រុស អនីតិជនឬនីតិជន មានសញ្ជាតិអ្វីក៏ដោយ ដោយវិធីល្បួងលោម សន្យាឱ្យប្រាក់កាសឬគ្រឿងអលង្ការឬតាមវិធីណាក៏ដោយ ទោះបីសាមីខ្លួនសុខចិត្តឬមិនសុខចិត្ត ដោយវិធីបង្ខិតបង្ខំ គំរាមកំហែងឬប្រើថ្នាំសណ្ដំស្មារតីនិងសតិអារម្មណ៍ ដើម្បីពង្រត់យកទៅលក់ឬ

យកទៅធ្វើពេស្យាចារ ជននោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំ ដល់ ១៥ឆ្នាំ ។ បើជនរងគ្រោះជាអនីតិជនអាយុតិចជាង ១៥ឆ្នាំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ឆ្នាំ ដល់ ២០ឆ្នាំ ។

អ្នកសមគំនិត អ្នកលក់ អ្នកទទួលទិញឬទទួលយក ត្រូវមានទោសដូចអ្នកប្រព្រឹត្តដែរ ។

ត្រូវចាត់ទុកជាអ្នកសមគំនិតដែរ អ្នកដែលផ្តល់ប្រាក់ឬផ្តល់មធ្យោបាយផ្សេងៗសម្រាប់ប្រព្រឹត្តបទល្មើស ។

មធ្យោបាយដឹកជញ្ជូន សម្ភារៈនិងទ្រព្យសម្បត្តិប្រើប្រាស់ ក្នុងពេលប្រព្រឹត្តបទល្មើសត្រូវរឹបអូសជាសម្បត្តិរដ្ឋ ។

## ជំពូកទី ៣
## អំពីសញ្ចារកម្ម

**មាត្រា ៤.-**

នឹងត្រូវចាត់ទុកជាសញ្ចារិកឬសញ្ចារិកាឬជនមេពេស្យា ជនណា :

១ - ដែលទំនុកបំរុងឬការពារជនណាម្នាក់ឬច្រើននាក់ ទោះបីតាមមធ្យោបាយណាក៏ដោយ ហើយដោយបានដឹងជាមុននូវអំពើពេស្យាចាររបស់ជននោះឬក៏ទាក់ទាញឱ្យជននោះ ក្នុងគោលដៅពេស្យាចារ ឬ

២ - ដែលចែកភាគផល ដែលបានមកពីអំពើពេស្យាចារជាប្រក្រតី ទោះជាក្នុងទ្រង់ទ្រាយណាក៏ដោយ ឬ

៣ - ដែលយកស្ត្រីឬបុរស ទោះបីតាមមធ្យោបាយណាក៏ដោយ ទៅបង្ហាត់បង្រៀនបញ្ចុះបញ្ចូលឱ្យធ្វើជាស្ត្រីឬបុរសពេស្យា ឬ

៤ - ដែលធ្វើជាអ្នកកណ្តាល ទោះបីតាមរូបភាពណាក៏ដោយ បង្កើតឱ្យមានទំនាក់ទំនងរវាងបុរសពេស្យាឬស្ត្រីពេស្យា ជាមួយនឹងមេបនពេស្យាចារឬជាមួយអ្នកផ្តល់កម្រៃលើពេស្យាចារអ្នកដទៃ ឬ

៥ - ដែលឱ្យបុរសឬស្ត្រី នៅក្នុងផ្ទះរបស់ខ្លួនឬកន្លែងណាមួយ ក្នុងគោលដៅឱ្យជនទាំងនោះធ្វើពេស្យាចារយកប្រាក់ឱ្យខ្លួន ។

**មាត្រា ៥.-**

សញ្ចារិកឬសញ្ចារិកាឬជនជាមេពេស្យា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ដល់ ១០ឆ្នាំ ។ ក្នុងករណីមិនរាងចាលត្រូវយកទ្វេរគុណនៃទោសមកអនុវត្ត ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំ ដល់ ២០ឆ្នាំ ក្នុងករណីសព្វារកម្ម :

១ - ប្រព្រឹត្តបទល្មើសលើអនីតិជនអាយុក្រោម ១៥ ឆ្នាំ ឬ

២ - ប្រព្រឹត្តបទល្មើសដោយបង្ខិតបង្ខំហិង្សាឬដោយមានការគំរាមកំហែងឬដោយ មានអាវុធ ឬ

៣ - ប្រព្រឹត្តដោយជា ស្វាមី ភរិយាឬសង្សារ ឬឪពុកឬម្តាយឬអាណាព្យាបាលដែលបង្ខំបុរសឬស្ត្រីឱ្យធ្វើពេស្យាចារ ឬ

៤ - ជាការបង្ខំឱ្យជនរងគ្រោះធ្វើពេស្យាចារនៅក្រៅប្រទេស ឬបង្ខំជនរងគ្រោះដែលជាបរទេសឱ្យធ្វើពេស្យាចារនៅលើទឹកដីកម្ពុជា ។

តុលាការអាចយកអនុទោសព្រង់ស្លានបន្ថយសិទ្ធិពលរដ្ឋ និងហាមស្នាក់អាស្រ័យមកផ្តន្ទាបន្ថែមពីលើមូលទោសខាងលើនេះបាន ។

**មាត្រា ៦.-**

អ្នកសមគំនិតឬអ្នកប៉ុនប៉ងប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ៤ និង ៥ ត្រូវទទួលទោសដូចអ្នកប្រព្រឹត្តដែរ ។

## ជំពូកទី ៤
## អំពីអនាចារ

**មាត្រា ៧.-**

ជនណាដែលបើកកន្លែងសម្រាប់ប្រព្រឹត្តអំពើអនាចារឬអំពើអាសអាភាសផ្សេងៗ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំ ដល់ ៥ឆ្នាំ និងពិន័យជាប្រាក់ពី ៥.០០០.០០០៛០០ "ប្រាំលានរៀល" ដល់ ៣០.០០០.០០០៛០០ "សាមសិបលានរៀល" ។ ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេជាពីរ ។

**មាត្រា ៨.-**

ជនណាដែលបានប្រព្រឹត្តអំពើអនាចារ លើអនីតិជនអាយុក្រោម ១៥ឆ្នាំ ទោះបីអនីតិជននោះស្ម័គ្រចិត្តក្តីឬដោយទិញក្មេងនោះពីអ្នកដទៃក្តីឬទិញពីជនជាមេពេស្យាក្តី ជននោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំ ដល់ ២០ឆ្នាំ ។ ក្នុងករណីមិនរាងចាល ត្រូវយកអតិបរមានៃទោសមកអនុវត្ត ។

តុលាការអាចយកអនុទោសព្រង់ស្លានបន្ថយសិទ្ធិពលរដ្ឋ និងហាមស្នាក់អាស្រ័យមកផ្តន្ទាបន្ថែមលើមូលទោសខាងលើនេះបាន ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**មាត្រា ៩.-**

ការណែនាំលំអិតសម្រាប់អនុវត្តច្បាប់នេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១០.-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ច្បាប់នេះ ត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ នាសម័យប្រជុំ
រដ្ឋសភាលើកទី ៥ នីតិកាលទី ១ ។

ភ្នំពេញ ថ្ងៃទី ខែ មករា ឆ្នាំ ១៩៩៦

ប្រធានរដ្ឋសភា

ជា ស៊ីម